ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០៧២/២៤ ក.ប/ស.ជ.ណ.ម.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# នីតិវិធីការប្រើប្រាស់ហត្ថពលកម្មបរទេសដោយស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានកិត្តិយស សូមរំលឹកដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស និងជនបរទេសដែលមកប្រកបមុខរបរណាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្នុងដែនអនុវត្តច្បាប់ស្តីពីការងារឱ្យបានជ្រាប អំពីនីតិវិធីការប្រើប្រាស់ហត្ថពលកម្មបរទេសដោយស្របច្បាប់ ដូចខាងក្រោម៖

ក. សម្រាប់សហគ្រាស គ្រឹះស្ថាន

- ដំណាក់កាលទី១៖ ស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនលើសពី ១០% នៃចំនួនកម្មករនិយោជិតខ្មែរសរុប
- ដំណាក់កាលទី២៖ ចុះបញ្ជិកាកិច្ចសន្យាការងារ
- ដំណាក់កាលទី៣៖ ស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស

ខ. សម្រាប់ជនបរទេស

- ដំណាក់កាលទី១៖ ស្នើសុំម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន បង្ហាញលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ដំណាក់កាលទី២៖ ចុះកិច្ចសន្យាការងារ ជាមួយម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន
- ដំណាក់កាលទី៣៖ ស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស

បន្ទាប់ពីទទួលបាន បណ្ណការងារ និងសៀវភៅការងារជនបរទេស ជនបរទេសអាចស្នើសុំទិដ្ឋាការការងារ នៅស្ថានតំណាងកម្ពុជានៅបរទេស ឬតាមប្រព័ន្ធអេឡិចត្រូនិច e.visa តាមគេហទំព័រ www.evisa.gov.kh ឬនៅច្រកទ្វារអន្តរជាតិកម្ពុជាដើម្បីចូលមកធ្វើការដោយស្របច្បាប់។

ជាមួយគ្នានេះ ក្រសួងក៏បានដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្ម លើការស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ការចុះបញ្ជិកាកិច្ចសន្យាការងារ និងការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស តាមរយៈគេហទំព័រ www.fwcms.mlvt.gov.kh។ សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យមើលលំហូរសង្ខេបលើខិត្តប័ណ្ណដូចមានភ្ជាប់មកជាមួយ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

សូមបញ្ជាក់ថា ជនបរទេសដែលប្រើប្រាស់ទិដ្ឋាការទេសចរណ៍ ឬទិដ្ឋាការដទៃទៀតដែលមិនមែនជាទិដ្ឋាការការងារ គឺមិនត្រូវបានអនុញ្ញាតឱ្យប្រកបមុខរបរ ឬធ្វើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស និងជនបរទេសដែលមកប្រកបមុខរបរណាមួយនៅព្រះរាជាណាចក្រកម្ពុជាជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ